# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកញ្ញា ឆ្នាំ២០២០

នៅក្នុងខែកញ្ញា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

ក-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រីរាជការ និងប្រជាពុទ្ធបរិស័ទ្ធចំណុះជើងវត្តប្រមាណជាង៣០០នាក់ នៅក្នុងបរិវេណវត្តសុវណ្ណគីរី (ជើងឆ្នុក) ស្ថិតក្នុងភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-បានអញ្ជើញចុះពិនិត្យសកម្មភាពស្ថានីយបូមទឹកវត្តចាស់ ដែលកំពុងដំណើរការបូមទឹករំដោះជំនន់ទឹកភ្លៀង ស្ថិតនៅក្នុងភូមិ១ សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញចុះជួបសួរសុខទុក្ខប្រជាពលរដ្ឋតាមខ្នងផ្ទះ នៅភូមិទី១៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញប្រារព្ធពិធីបង្សុកូលជូនដល់វិញ្ញាណក្ខន្ធ មាតា បិតា ញាតិកាទាំង៧សន្តាន ដែលបានចែកឋានទៅលោកខាងមុខ នៅវត្តសុវណ្ណគិរី (ហៅវត្តជើងឆ្នុក) នៅភូមិជើងឆ្នុក ឃុំតាំងក្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-បានអញ្ជើញប្រារព្ធពិធីបុណ្យកាន់បិណ្ឌវេនទី១ និងបង្សុកូលជាឆ្លង វេរទេយ្យទានប្រគេនព្រះសង្ឃឧទ្ទិសកុសលផលបុណ្យ ជូនចំពោះបុព្វការីជន ញាតិកាទាំង៧សន្តានឥស្សរជន និងយុទ្ធជនដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជា ស៊ីម**



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

នៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធឆ្លងឧបដ្ឋានសាលា សមិទ្ធផលនានា និងចូលរួមកាន់បិណ្ឌវេនទី៦ នៅវត្តឧប្បលវតី (ហៅវត្តឈូក) ស្ថិតនៅក្នុងឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ

-បានអញ្ជើញនាំយកគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១២ នៅវត្តគោកពិសីវ័ត្ន ( ហៅវត្តគោកអំពិល ) សង្កាត់ជើងឯក ខណ្ឌដង្កោ និងនៅវត្តឥន្ទសុវណ្ណ (ហៅវត្តអង្គស្លុក) សង្កាត់ឪឡោក ខណ្ឌកំបូល រាជធានីភ្នំពេញ

-បានអញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធ បុព្វការីជន និងញាតិកាទាំង៧សន្តានរបស់សម្តេច ស្ថិតនៅភូមិទី១០ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-បានអញ្ជើញប្រារព្ធពិធីបុណ្យជីវិកភត្តទានជូនឧបាសក **លាវ ហាន** ឧបាសិកា **ឡៅ គីមហុង** បុព្វការីជនទាំងឡាយដែលកំពុងមានព្រះជន្ម និងប្រារព្ធសង្ឃតាទក្ខិណា-នុប្បទានបង្សុកូលជូនដល់ដួងវិញ្ញាណក្ខន្ធ មាតា បិតា បុព្វការីជន ញាតិកាទាំង៧សន្តាន ដែលបានចែកឋានទៅលោកខាងមុខ នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-បានអញ្ជើញប្រារព្ធពិធីបង្សុកូល ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន យុទ្ធជន យុទ្ធនារី ដែលបានពលីជីវិត ដើម្បីបុព្វហេតុរំដោះជាតិមាតុភូមិ ក្នុងសម័យតស៊ូ នៅចេតិយពាមអំពិល ជាទីសក្ការៈដែលប្រជាជនតែងតែទៅគោរពវិញ្ញាណក្ខន្ធ ស្ថិតក្នុងភូមិពង្រខាងលិច ឃុំពង្រ ស្រុកកោះសូទិន និងនៅក្នុងបរិវេណវត្តមហាលាភ ភូមិមហាលាភ ឃុំមហាលាភ ស្រុកកោះសូទិន ខេត្តកំពង់ចាម

-បានអញ្ជើញចូលរួមរំលែកទុក្ខជាមួយនឹងក្រុមគ្រួសារសពឧបាសិកា **សាន ស៊ុនលន** និងឧបាសិកា **ជាម ស្រ៊ាន** នៅសារមន្ទីរនរៈបុរី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងនៅសង្កាត់បឹងព្រលឹត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៨ច្បាប់។

## ១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ីម កា** អនុប្រធានទី១ព្រឹទ្ធសភា

### ក-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម **យង់ ពៅ** អគ្គលេខាធិការរាជបណ្ឌិតសភាកម្ពុជា តំណាងឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ប្រធានរាជបណ្ឌិតសភាកម្ពុជា និងក្រុមការងារចូលជួបសម្ភាសន៍ ដើម្បីរៀបចំគុណកថាលម្អិតសម្រាប់ពិធីប្រកាសគោរមងារកិត្តិយសដែល **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ត្រាស់បង្គាប់គោរមងារកិត្តិយសនៃរាជបណ្ឌិតសភាកម្ពុជា ជា "កិត្តិនីតិកោសលបណ្ឌិត"។

### ខ-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញប្រារព្ធពិធីបុណ្យកាន់បិណ្ឌវេនទី១ និងបង្សុកូលជាឆ្លង វេរទេយ្យទានប្រគេនព្រះសង្ឃឧទ្ទិសកុសលផលបុណ្យ ជូនចំពោះបុព្វការីជនញាតិកាទាំង៧សន្តានឥស្សរជន និងយុទ្ធជនដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជា ស៊ីម** នៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-បានអញ្ជើញចូលរួមកាន់បិណ្ឌទី១៤ និងបាននាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ និងបច្ច័យ ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្តជ្រៃម្រាក់ និងបាននាំយកនូវថវិកាឧបត្ថម្ភជូនលោកគ្រូ អ្នកគ្រូ និងនាំយកអំណោយមួយចំនួន រួមមាន ៖ កាបូបសៀវភៅ ប៊ិច ខ្មៅដៃ និងថវិកាមួយចំនួនចែកជូនសិស្សានុសិស្សចំនួន៥០០នាក់ នៅសាលាបឋមសិក្សាវត្តអញ្ញាញ ស្ថិតនៅភូមិជ្រៃម្រាក់ ឃុំគោកគង់កើត ស្រុកកំចាយមារ ខេត្តព្រៃវែង

-បានអញ្ជើញចូលរួមពិធីបុណ្យភ្ជុំបិណ្ឌ និងបង្សុកូលឧទ្ទិសកុសលជូនជីដូន ជីតា បុព្វការីជន ញាតិកាទាំង៧សន្តាន និងបាននាំយកនូវគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ និងបច្ច័យ ទៅវេរប្រគេនព្រះសង្ឃគង់នៅវត្ត និងបានចែកជូននូវថវិកា សម្ភារៈជាទេយ្យទាន ដល់លោកតា លោកយាយ ព្រមទាំងចូលបច្ច័យចំនួន១០.៥០០.០០០រៀល និង៧០០ដុល្លារ ដើម្បីបន្តកសាងសមិទ្ធផលនានាក្នុងវត្ត នៅវត្តទេពនិម្មិត (ហៅវត្តអញ្ញាញ) ស្ថិតនៅឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក.សកម្មភាពចូលរួមប្រជុំ**

-បានអញ្ជើញចូលរួមប្រជុំកិច្ចការផ្ទៃក្នុង ក្រោមអធិបតីភាពសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញប្រារព្ធពិធីបុណ្យកាន់បិណ្ឌវេនទី១ និងបង្សុកូលដាឆ្លង វេរទេយ្យទានប្រគេនព្រះសង្ឃឧទ្ទិសកុសលផលបុណ្យ ជូនចំពោះបុព្វការីជន ញាតិកាទាំង៧សន្តាន ឥស្សរជន និងយុទ្ធជនដែលបានពលីជីវិត ដើម្បីជាតិមាតុភូមិ ជាពិសេសជូនដល់ដួងវិញ្ញាណក្ខន្ធសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជា ស៊ីម** នៅភូមិកន្លែងជ្រៅ ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង

-បានអញ្ជើញនាំយកបច្ច័យ ទេយ្យទាន និងចង្ហាន់ប្រគេនព្រះសង្ឃ ដើម្បីចូលរួមពិធីកាន់បិណ្ឌវេនទី៤ចំនួន០៥វត្ត ដើម្បីឧទ្ទិសកុសលផលបុណ្យជូនដល់ញាតិកាទាំង៧សណ្តាន ដែលបានចែកឋានទៅកាន់លោកខាងមុខ និងបានយកម៉ាស់ អាល់កុល និងសាប៊ូ ប្រគេនព្រះចៅអធិការវត្ត ជូនអាជ្ញាធរ និងលោកគ្រូ អ្នកគ្រូ ស្ថិតក្នុងស្រុកទ្រាំង ខេត្តតាកែវ

-បានអញ្ជើញចូលរួមអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ឧបដ្ឋានសាលា និងពិធីកាន់បិណ្ឌវេនទី៦ នៅវត្តឧប្បលវតី ស្ថិតក្នុងឃុំឈូក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ និងចូលរួមពិធីបង្សុកូលជូនញាតិកាទាំង៧សណ្តាន នៅស្រុកកោះសូទិន ខេត្តកំពង់ចាម

-បានអញ្ជើញចូលរួមក្នុងពិធីធ្វើបទនមស្សការ សមាទានសីល ចម្រើនព្រះបរិត្ត សម្តែងព្រះធម៌ទេសនា ក្នុងពិធីបុណ្យទក្ខិណានុប្បទានគម្រប់ខួប១ឆ្នាំ ឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធឯកឧត្តមនាយឧត្តមសេនីយ៍ព្រឹទ្ធាចារ្យ **ប៊ូ ថង** អតីតសមាជិកព្រឹទ្ធសភា នៅខេត្តរតនគិរី

-បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នាំយកបច្ច័យ ទេយ្យទាន និងចង្ហាន់ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១១ នៅវត្តមុនីប្រសិទ្ធីវង្ស

-បានអញ្ជើញអមដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភានាំ

យកគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ និងបច្ច័យ ចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១២ នៅវត្តគោកពិសីវ័ន្ត (ហៅវត្តគោកអំពិល) សង្កាត់ជើងឯក ខណ្ឌដង្កោ និងនៅវត្តឥន្ទសុវណ្ណ (ហៅវត្តអង្គស្តុក) សង្កាត់ឪឡោក ខណ្ឌកំបូល រាជធានីភ្នំពេញ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់។

## ២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

ក្នុងខែកញ្ញានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ២.១ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីផ្សព្វផ្សាយអំពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធ-សភា និងសិក្សាឈ្វេងយល់អំពីបញ្ហាប្រឈម ព្រមទាំងសំណូមពររបស់អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយផ្តោតលើ (១).ឈ្វេងយល់អំពីការអនុវត្តវិធានការ បង្ការ ទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ (២).ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ (ការផ្តល់បណ្ណសមធមិជូនគ្រួសារក្រីក្រក្នុងដំណាក់កាលប្រឈមនឹងជំងឺកូវីដ-១៩) (៣).ការងារអត្រានុកូលដ្ឋាន (៤).ការងារអភិវឌ្ឍន៍មូលដ្ឋាន និង(៥).ការអនុវត្តគោលនយោបាយភូមិឃុំ មានសុវត្ថិភាពនៅខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-បានអញ្ជើញជួបជាមួយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញមន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍អំពីការវិវត្តរីកចម្រើនថ្មី បញ្ហាប្រឈម និងវិធានការនានា ព្រមទាំងបានផ្តល់នូវអនុសាសន៍មួយចំនួន ពិសេសត្រូវគោរពតាមការណែនាំរបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចូលរួមទប់ស្កាត់ការរាតត្បាតជំងឺកូវីដ-១៩ នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការវិវត្តរីកចម្រើនថ្មី បញ្ហាប្រឈម វិធានការ ចក្ខុវិស័យទៅមុខរបស់អាជ្ញាធរខេត្ត និងវិស័យពាក់ព័ន្ធជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ

-បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយមេឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ដើម្បីសិក្សាឈ្វេងយល់ពីការអនុវត្តសិទ្ធិមនុស្ស ការអនុវត្តច្បាប់ និងការដោះស្រាយពាក្យបណ្តឹង ព្រមទាំងបញ្ហាប្រឈម ការលំបាក និងសំណូមពរនានារបស់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំខណ្ឌសែនសុខ ដឹកនាំដោយលោក **ម៉ូវ ម៉ានិត** អភិបាល នៃគណៈអភិបាលខណ្ឌ ក្រោមប្រធានបទស្តីពីដំណើរការនៃសមាហរណកម្មការិយាល័យជំនាញទាំង១១នៃរដ្ឋបាលខណ្ឌ និងការអនុវត្តផែនការរដ្ឋបាល នៅសាលាខណ្ឌសែនសុខ រាជធានីភ្នំពេញ

-បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ អាជ្ញាធរខេត្ត មន្ទីរពាក់ព័ន្ធជុំវិញខេត្ត រួមទាំងកងកម្លាំងប្រដាប់អាវុធ ដើម្បីសិក្សាឈ្វេងយល់ និងសម្រង់ព័ត៌មានដែលពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈ-កម្មការ

-បានអញ្ជើញទស្សនកិច្ចដំណើរការផលិតចំណីសត្វរបស់រោងចក្រអិមភី(MP) កសិដ្ឋានចិញ្ចឹមជ្រូកទី៣ខាងលិចជើងភ្នំបូកគោ និងទស្សនាដំណើរការសាងសង់កសិដ្ឋានចិញ្ចឹមជ្រូក ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ទំនប់ទឹកទាំងពីរកន្លែង និងរោងចក្រចម្រាញ់ដូងប្រេងទី២អន្លង់ក្រពើ។

## ២.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៩ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន០៥ករណី និងកំពុងពិនិត្យសិក្សាចំនួន១១ករណី ព្រមទាំងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធ ចំនួន០១ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបបានចំនួន០៣ករណី

-បានអញ្ជើញជួបពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ក្នុងក្រុងប៉ោយប៉ែត ស្រុកអូរជ្រៅ និងស្រុកព្រះនេត្រព្រះ ដើម្បីសិក្សាឈ្វេងយល់អំពីការផ្តល់សេវារដ្ឋបាល ការងារមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព នៅខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប

-បានអញ្ជើញចូលរួមពិធីផ្សព្វផ្សាយរបាយការណ៍ស្ថិតិយេនឌ័រស្តីពី បញ្ហាប្រឈមរបស់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងលទ្ធផលស្រាវជ្រាវគន្លឹះនៃការវិភាគស្ថិតិយេនឌ័រ ក្រោមអធិបតីភាពលោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ រដ្ឋសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខ ចែកអំណោយ និងអប់រំផ្សព្វផ្សាយវិធីបង្ការ និងទប់ស្កាត់ជំងឺកូវីដ១៩ (Covid-19) ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ភោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តក្រុងនានាចំនួន២៤៩លើក។

## ២.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-គណៈកម្មការទី២ ទី៥ ទី៨ និងទី៩ បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការស្ត្រី គណៈកម្មាធិការនយោបាយ គណៈកម្មាធិការសមាជិកសភាអាយប៉ាវ័យក្មេង គណៈកម្មាធិការសង្គមកិច្ច គណៈកម្មាធិការសេដ្ឋកិច្ចអាយប៉ា(AIPA) លើកទី៤១ តាមប្រព័ន្ធវីដេអូ(Conference) ដែលសភាប្រទេសវៀតណាមធ្វើជាម្ចាស់ផ្ទះ

-ឯកឧត្តម **ម៉ុង ឫទ្ធី** បានជួបពិភាក្សាការងារជាមួយក្រុមហ៊ុនបើកបរយានយន្តយ៉ាម៉ាម៉ូតូ Yamamoto និងសហព័ន្ធកីឡាប្រណាំងយានយន្តកម្ពុជា ដើម្បីជួយជំរុញលើវិស័យកីឡាប្រណាំងយានយន្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ថ្ងៃច័ន្ទ ៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០២០

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ